រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

សម្រាប់ការផ្សាយបន្ទាន់
ថ្ងៃ ពុធ ទី ១៧ ខែ សីហា ឆ្នាំ ២០១១

## របាយការណ៍សំយោគទី ២៦ របស់*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ

## វិស័យកាត់ដេរបន្តការងើបឡើង ហើយការអនុលោមតាមច្បាប់ ជារួមមានកម្រិតខ្ពស់ បើទោះបីជានៅមានបញ្ហាប្រឈមមួយចំនួន

ភ្នំពេញ ប្រទេសកម្ពុជា- *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ (ILO) នៅថ្ងៃនេះ ចេញផ្សាយនូវ*របាយការណ៍សំយោគទី ២៦ ស្តីពីល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរកម្ពុជា* ដែលធ្វើការវាយតំលៃលើការអនុលោមតាមច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា និងបទដ្ឋានការងារអន្តរជាតិនៅក្នុងរោងចក្រកាត់ដេរនាំចេញ។

របាយការណ៍សំយោគទី ២៦ នេះឆ្លុះបញ្ចាំងពីទិន្នន័យនៃការអនុលោមតាមច្បាប់ ដែលប្រមូលបាននៅចន្លោះពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១០ ដល់ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១១។ នៅក្នុងរយៈពេល ៦ ខែនេះ ក្នុងចំណោមរោងចក្រសរុបចំនួន២៧៦ ដែលបានចុះបញ្ជិកាជាមួយ*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* មានរោងចក្រចំនួន១៨៦ ត្រូវបានធ្វើការត្រួតពិនិត្យនូវល័ក្ខខ័ណ្ឌការងារ។ របាយការណ៍ត្រួតពិនិត្យល័ក្ខខ័ណ្ឌការងារនេះ ផ្តល់នូវព័ត៌មានជាច្រើនរួមមានព័ត៌មានអំពីទំហំរោងចក្រនៅទូទាំងវិស័យនេះ ក៏ដូចជាទិន្នន័យប្រៀបធៀបអំពីការអនុលោមតាមសិទ្ធិជាមូលដ្ឋាន និងល័ក្ខខ័ណ្ឌការងារសំខាន់ៗមួយចំនួនដើម្បីសម្រួលដល់ការតាមដាននូវកម្រិតនៃការអនុលោមតាមច្បាប់នាពេលកន្លងមក។

យោងតាមទិន្នន័យពីក្រសួងពាណិជ្ជកម្មបានឱ្យដឹងថា ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១១ មានកម្មករនិយោជិតចំនួន ៣២៨៤៧៦ នាក់បម្រើការងារនៅក្នុងរោងចក្រកាត់ដេរនាំចេញចំនួន ២៨៦ ដែលបានចុះបញ្ជិកាជាមួយនឹងក្រសួងពាណិជ្ជកម្ម។ ហើយមានសំណើវិនិយោគទុនបើករោងចក្រកាត់ដេរថ្មីចំនួន២៦ ត្រូវបានអនុម័តយល់ព្រមនៅក្នុងរយៈពេល ៦ ខែដំបូងក្នុងឆ្នាំ ២០១១ នេះ។ បើយោងតាមទិន្នន័យពីក្រសួងពាណិជ្ជកម្ម ការនាំចេញនូវសម្លៀកបំពាក់បានកើនឡើងចំនួន ៣២% នៅក្នុងរយៈពេល ៦ ខែដំបូងក្នុងឆ្នាំ ២០១១ បើប្រៀបទៅនឹងរយៈដូចគ្នាក្នុងឆ្នាំ ២០១០។

ជាទូទៅ កម្រិតនៃការអនុលោមតាមច្បាប់នៅតែមានកម្រិតខ្ពស់ បើទោះបីជានៅមានបញ្ហាកង្វល់មួយចំនួន ជាពិសេសទាក់ទងទៅនឹងការរើស

Better Factories Cambodia
International Labour Organization

#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642

Tel (+855) 23 212 847
(+855) 23 220 362
ext. 106/7
Fax (+855) 23 212 903
E-mail betterfactories@ilo.org
Website www.betterfactories.org/ilo

អើង ការធ្វើការបន្ថែមម៉ោង សុខភាពនិងសុវត្ថិភាពការងារ។ ចំនួនកូដកម្មដែលអនុលោមតាមនិតិវិធីច្បាប់មុននឹងធ្វើកូដកម្ម នៅតែជាបញ្ហាកង្វល់។

លទ្ធផលដែលបានរកឃើញសំខាន់ៗមួយចំនួន មានដូចតទៅ ÷

- កម្មករនិយោជិតជាង៣ភាគ៤ ធ្វើការនៅក្នុងរោងចក្រដែលមានកម្មករចំនួន ១០០០ នាក់ឬច្រើនជាងនេះ ប៉ុន្តែរោងចក្រភាគច្រើនដែលត្រូវបានត្រួតពិនិត្យ មានកម្មករនិយោជិតតិចជាង ១០០០ នាក់។
- រោងចក្រចំនួន ៧៦% ដែលត្រូវបានពិនិត្យមើលនូវល័ក្ខខ័ណ្ឌការងារដោយ *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* មានសហជីពយ៉ាងហោចណាស់មួយ ពោលគឺបានកើនឡើងចំនួន ៣% បើធៀបនឹងរបាយការណ៍សំយោគទី២៥។
- រោងចក្រដែលបានរើសអើងចំពោះកម្មករនិយោជិត គឺមានចំនួន ១៣% ពោលគឺកើនឡើងពី៨%នៅក្នុងរបាយការណ៍មុន ហើយរោងចក្រដែលមានការរើសអើងប្រឆាំងនឹងសហជីពគឺមានចំនួន ៣% ពោលគឺធ្លាក់ចុះពី ៥% ចំណែកឯរោងចក្រដែលរំខានដល់សេរីភាពរបស់កម្មករនិយោជិតក្នុងការបង្កើតអង្គការវិជ្ជាជីវៈមានចំនួន ២% ពោលគឺធ្លាក់ចុះពី ៤%។
- មន្ត្រីត្រួតពិនិត្យល័ក្ខខ័ណ្ឌការងារ ពុំបានរកឃើញនូវពលកម្មដោយបង្ខំឡើយ ហើយក៏គ្មានកម្មករនិយោជិតណាមួយស្ថិតក្រោមអាយុធ្វើការដែលកំណត់ដោយច្បាប់ ពោលគឺក្រោមអាយុ១៥ឆ្នាំនោះទេ។
- រោងចក្រចំនួន ២១% ក្នុងចំណោមរោងចក្រទាំងឡាយដែលត្រូវបានពិនិត្យល័ក្ខខ័ណ្ឌការងារ មានការធ្វើកូដកម្ម ដែលភាគរយនេះបានកើនឡើង ពី ១៣% នៅក្នុងរបាយការណ៍មុន។ កូដកម្មដើម្បីតម្លើងប្រាក់ឈ្នួលដែលបានកើតឡើងកាលពីខែកញ្ញា ឆ្នាំ២០១០ បានធ្វើឱ្យតួលេខនៃចំនួនកូដកម្មមានការកើនឡើង។
- ការអនុលោមតាមល័ក្ខខ័ណ្ឌប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតពេញសិទ្ធិ គឺនៅមានកម្រិតខ្ពស់ (ចំនួន ៩៧%) បើទោះជាចំនួននេះបានធ្លាក់ចុះបន្តិចពី៩៩% បើប្រៀបធៀបនឹងរបាយការណ៍មុន។ ចំណែកនៅក្នុងរោងចក្រដែលមានកម្មករនិយោជិតម្តងម្កាលវិញ កម្រិតនៃការអនុលោមតាមច្បាប់ក្នុងការផ្តល់ប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិតទាំងនោះ គឺមានចំនួន ៧៩% ពោលគឺធ្លាក់ចុះពី៨៩%ក្នុងរបាយការណ៍មុន។
- រោងចក្រចំនួន ៩៧% បានផ្តល់ការឈប់សម្រាកប្រចាំឆ្នាំរយៈពេល ១៨ ថ្ងៃដល់កម្មករនិយោជិត ដោយផ្តល់ឱ្យជាថ្ងៃឈប់សម្រាក ឬជាថវិកាជំនួស។ ការអនុលោមទៅនឹងល័ក្ខខ័ណ្ឌប្រាក់ឈ្នួលសម្រាប់ការឈប់សម្រាកលំហែមាតុភាព កើនឡើងចំនួន ១៨% រហូតដល់ ៧៣% ខណៈពេលដែលការអនុលោមតាមល័ក្ខខ័ណ្ឌនៃការឈប់សម្រាកឈឺដោយមានប្រាក់ឈ្នួល បានធ្លាក់ចុះចំនួន ២% មកត្រឹម ៧៧% បើប្រៀបធៀបជាមួយនឹងរបាយការណ៍មុន។
- ការអនុលោមទៅតាមច្បាប់ស្តីពីកំហិតភាពញឹកញាប់ និងរយៈពេលនៃការធ្វើការបន្ថែមម៉ោង បានធ្លាក់ចុះចំនួន១% និង ២% បើប្រៀបធៀបនឹងរបាយការណ៍មុន ហើយការអនុលោមតាមច្បាប់ស្តីពីការធ្វើការបន្ថែមម៉ោងដោយមានការស្ម័គ្រចិត្ត ក៏បានធ្លាក់ចុះចំនួន១% មកនៅត្រឹម ៨៩%។
- ការអនុលោមទៅតាមល័ក្ខខ័ណ្ឌផ្តល់ឧបករណ៍ការពារខ្លួនដល់កម្មករនិយោជិត បានថយចុះចំនួន ២% ចំណែកឯការអនុលោមទៅតាមល័ក្ខខ័ណ្ឌតម្លើងរបាំងការពារម្ជុលលើម៉ាស៊ីនដេរ បានធ្លាក់ចុះចំនួន ៨%។

- ក្នុងចំណោមបញ្ហាធំៗចំនួន ១០ ដែលមិនបានអនុលោមតាមច្បាប់ មានបញ្ហាចំនួន៧ ពាក់ព័ន្ធនឹងការធ្វើការបន្ថែមម៉ោង និងសុខភាពនិងសុវត្ថិភាពការងារ ដែលនេះបានឆ្លុះបញ្ចាំងពីបញ្ហាដ៏តឹងតែង ដែលនិយោជកជួបប្រទះនៅក្នុងការដោះស្រាយនូវបញ្ហាទាំងនេះ។ តែទោះបីយ៉ាងណាក៏ដោយ ក៏មានការកែលំអនូវល័ក្ខខ័ណ្ឌមួយចំនួនដែលពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារ។

ខណៈពេលដែលមានភាពប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារនៅក្នុងឧស្សាហកម្មកាត់ដេរ ក៏នៅតែមានបញ្ហាកង្វល់មួយចំនួនដែលកំពុងប្រឈម។ បញ្ហាប្រឈមទាំងនេះ រួមមានការយកចិត្តទុកដាក់លើបញ្ហាសុខភាពនិងសុវត្ថិភាពការងារ ការអនុវត្តនូវកិច្ចសន្យាការងារ និងសិទ្ធិសហជីព។ ក្នុងពេលដែលឧស្សាហកម្មនេះបាននឹងកំពុងងើបឡើងពីវិបត្តិហិរញ្ញវត្ថុ និងមានការកើនឡើងនូវចំនួនកម្មករនិយោជិតនោះ វាមានសារៈសំខាន់ក្នុងការបន្តការយកចិត្តទុកដាក់លើការធ្វើឱ្យប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារ ដែលពាក់ព័ន្ធនឹងទំនាក់ទំនងរវាងអ្នកគ្រប់គ្រង និងកម្មករនិយោជិត និងផលិតភាព។

របាយការណ៍សំយោគទី ២៦ ស្តីពីល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរនៅកម្ពុជា មានជាភាសា**ខ្មែរ** **អង់គ្លេស** និង**ចិន** ដែលអាចរកបាននៅលើគេហទំព័រ www.betterfactories.org ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:
លោក ប៊ុន យិញ
មន្ត្រីទំនាក់ទំនងព័ត៌មាន
អ៊ីម៉ែល: ying@ilo.org
ទូរស័ព្ទ: ០១២ ៩០ ២៩ ៩០